# គម្រោងបង្ហាញបច្ចេកវិទ្យា ដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប (TSTD)

ADB TA 7305-CAM

## បច្ចេកទេសបណ្ដុះផ្សិតចំបើងតាមបែបចំហុយ





បទបង្ហាញដោយៈ លោក **អ៊ួន ប៊ុនណារិទ្ធ**

ជំនាញការផ្នែកទីផ្សារ



**បន្ទាយមានជ័យ ថ្ងៃទី ០៧ កញ្ញា ឆ្នាំ ២០១១**

# មាតិកា

1. វដ្តរបស់ផ្សិតចំបើង
២. វិធីបណ្តុះផ្សិតចំបើង
៣. តម្រូវការលូតលាស់របស់ផ្សិតចំបើង
៤. បច្ចេកទេសបណ្តុះផ្សិតចំបើងបែបចំហុយ
    ៤.១ ការលាយល្បាយនិងរៀបចំដុំល្បាយកំប៉ុស្តិ
    ៤.២ ការចំហុយដុំល្បាយកំប៉ុស្តិ
    ៤.៣ ការបញ្ចូលមេផ្សិត (ស្ព័រ)ក្នុងដុំល្បាយកំប៉ុស្តិ
    ៤.៤ ការសាងសង់រោង
    ៤.៥ ការបន្ទុំដុំល្បាយកំប៉ុស្តិ
    ៤.៦ ការព្យួរនិងការថែទាំដុំល្បាយកំប៉ុស្តិ
    ៤.៧ ការប្រមូលផល

# ១. វដ្តរបស់ផ្សិតចំបើង



# ២. វិធីបណ្តុះផ្សិតចំបើង

## វិធីបណ្តុះផ្សិតចំបើងតាមបែបចំហុយ ដោយដុំល្បាយកំប៉ុស្តិ








## វិធីបណ្តុះផ្សិតចំបើងតាមបែបចំហុយ ដោយបាញ់ចំហាយទឹក





# ៣. តម្រូវការលូតលាស់របស់ផ្សិតចំបើង

## លក្ខខ័ណ្ឌនៃការដុះលូតលាស់

- ផ្សិតចំបើងត្រូវការអាកាសធាតុក្តៅហើយសើម
- កំដៅកើតមកពីកំប៉ុស្តិកម្មរបស់ដុំល្បាយបណ្តុះជាមួយនឹងសំណើមសមស្រប ក្នុងកន្លែងហាប់
- ផ្សិតអាចលូតលាស់បានល្អដោយស្រូបយកសារធាតុចិញ្ចឹមពីល្បាយកំប៉ុស្តិបណ្តុះដាក់ក្នុងកន្លែងមានកំដៅសមស្រប (៣២-៣៨អង្សារ)

## រូបភាព





# ៤. បច្ចេកទេសបណ្តុះផ្សិតចំបើងបែបចំហុយ

## ៤.១ ការលាយល្បាយនិងរៀបចំដុំល្បាយកំប៉ុស្តិ

- វត្ថុធាតុដើមសម្រាប់ លាយធ្វើល្បាយកំប៉ុស្តិ រួមមាន៖

- ក-ចំបើង ឬគល់កញ្ច្រាំង ចំនួន១០០ គីឡូក្រាម (បើមាន លាយជាមួយកំប្លោក ក្រៀម ដើមចេក ចិតហាលក្រៀម កាក អំពៅ សំបកដំឡូង សំបកសណ្តែកបាយ កំទេចស្លឹលពោត ឬ ស្លូលគ) ចំនួន ១០០គីឡូក្រាម

## រូបភាព

- ខ-កន្ទក់ម៉ត់ ចំនួន  ៨-១០គីឡូក្រាម
- គ-ចុងអង្ករ (ឬ ម្សៅដំណើប ម្សៅពោត)ចំនួន១គីឡូក្រាម
- ឃ-កំបោរស ចំនួន០,៥គីឡូក្រាម
- ង-ជីអ៊ុយរ៉េ (លាយទឹកស្រេច)ចំនួន ០,៥គីឡូក្រាមឬជីលាមកសត្វក្រៀមពី ៥ទៅ១០គីឡូក្រាម។
- ច-ទឹកស្អាតលាយល្បាយ (សំណើម ៦០-៧០%)







# ៤. បច្ចេកទេសបណ្ដុះផ្សិតចំបើងបែបចំហុយ (ត)

រូបភាព

## ៤.២ ការចំហុយដុំល្បាយកំប៉ុស្តិ

- ដុំល្បាយចាំបាច់ត្រូវចំហុយក្នុងធុងសាំងឲ្យបានឆ្អិនល្អ(ឲ្យពុះជាប់៣-៤ម៉ោង)ដើម្បីចៀសវាងកុំឲ្យដុះផ្សិតអាចម៍គោ
- ដើម្បីចំហុយបានងុំល្អ និងសន្សំសំចៃអុសអ្នកបណ្ដុះផ្សិតត្រូវរៀបចំ ចង្ក្រានគុកប្រើអង្កាម
- ស្រង់ដុំល្បាយទុកសំដិលឲ្យត្រជាក់ (រយៈពេល១២ម៉ោង)






# ៤. បច្ចេកទេសបណ្ដុះផ្សិតចំបើងបែបចំហុយ (ត)

៤.៣ ការបញ្ចូលមេផ្សិត (ស្ព័រ)ក្នុងដុំល្បាយ

- ប្រើមេផ្សិតមានគុណភាពល្អសម្រាប់បណ្ដុះផ្សិត។ ជ្រើសរើសទីកន្លែងស្អាត បិទជិតគ្មានខ្យល់បក់ សម្រាប់បញ្ចូលមេផ្សិត
- សំអាតដៃនិងសំភារៈដោយអាល់កុល
- ស្រាយមាត់ ថង់ដុំល្បាយម្ខាងម្ដងៗដើម្បីដាក់បញ្ចូលមេផ្សិត
- បន្ទាប់ពីបញ្ចូលមេរួចដាក់កងទុយោរួចគ្របក្រដាស មុននឹងចងមាត់ថង់នឹងកៅស៊ូកង

## រូបភាព



# ៤. បច្ចេកទេសបណ្តុះផ្សិតចំបើងបែបចំហុយ (ត)

រូបភាព

## ៤.៤ ការសាងសង់រោង

- រោងនេះធ្វើពី រសរ បង្កាល ឈើឬឬស្សីនិងរនាបឬស្សី សម្រាប់ធ្វើបង្កោង ដំបូលដូចដំបូលទូក
- ដំបូលនិងជញ្ជាំងហ៊ុំព័ទ្ធដោយកៅស៊ូប្លាស្ទិច
- ដើម្បីរក្សាកំដៅបានល្អតាមធម្មតាគេ សង់រោងនេះមានកំពស់ ពី ១,២ម៉ែត្រ ទៅ១,៧ ម៉ែត្រ





# ៤. បច្ចេកទេសបណ្តុះផ្សិតចំបើងបែបចំហុយ (ត)

## ៤.៥ ការបន្ទុំដុំល្បាយកំប៉ុស្តិ

- ការបន្ទុំដុំល្បាយត្រូវការកន្លែងបិទបាំងមិនឲ្យមានខ្យល់ចេញចូល និងកំដៅខ្លាំង
- យកភួតង់កៅស៊ូមកក្រាល រួចហើយយកដុំល្បាយដែលបានបញ្ចូលមេរួច មកតម្រៀប ទល់មុខគ្នាដាក់ជួរនិងគរលើគ្នាជាសាជីៗ រួចហើយបត់ ជាយតង់កៅស៊ូខ្ទប់រុំដូចជាភួយ
- តាមដានកំដៅដុំ ល្បាយធ្វើយ៉ាងណាឲ្យប្រហាប់ក្តៅងំហើយត្រូវត្រឡប់ បង្វិលចង់នៅថ្ងៃទី៦បន្ទាប់ពីដាក់បន្ទុំ។

## រូបភាព

- ការបន្ទុំអាចត្រូវការពេលពី៨ទៅ១២ថ្ងៃទើបសរសៃរមេផ្សិតដើរសព្វជុំវិញផ្ទៃដុំល្បាយ



# ៤. បច្ចេកទេសបណ្តុះផ្សិតចំបើងបែបចំហុយ (ត)

## ៤.៦ ការព្យួរនិងថែទាំដុំល្បាយកំប៉ុស្តិ

- ពេលសរសៃរមេផ្សិតដើរសព្វជុំវិញផ្ទៃដុំល្បាយហើយត្រូវស្រាយយ៉ូលលាថង់ស្រោបខាងក្រៅចេញហើយស្រោចទឹកពីលើដុំល្បាយឲ្យជោគល្អ(ស្រោចផ្កាច់សសៃពីងពាង

- ចូក់ខ្សែដុំ ល្បាយនឹងទំពក់ដែក រួចហើយព្យួរនឹងស្នួលឬស្សី ម្តងមួយកុំឲ្យប៉ះ គ្នាក្នុងរោងបណ្តុះ។បន្ទាប់ពីព្យួររួច ត្រូវបិទរោងបណ្តុះ ឲ្យជិតនឹងសង្កត់ ជើងថង់ជាប់ដីផង។ពិនិត្យតាមដាន កំដៅនិងសំណើមដុំបណ្តុះ

## រូបភាព

- បើសូតពេកត្រូវបាញ់ផ្សើមចំហាយទឹក(កំប៉ុស្តិ)។ត្រូវរក្សាកំដៅឲ្យបានសមស្រប ជានិច្ច(៣៥-៣៨អង្សារ)



# ៤. បច្ចេកទេសបណ្តុះផ្សិតចំបើងបែបចំហុយ (ត)

## ៤.៧ ការប្រមូលផល

- ក្រោយពេលព្យួរពី៨ទៅ១០ថ្ងៃ ផ្សិតចាប់ផ្ដើមដុះ ។ គេត្រូវបេះផ្សិតពេលព្រឹកព្រលឹមដោយកាត់យកកញ្ចុំផ្សិតណាដែលមានធំសមស្រប

- ប្រទ្បេះយកផ្សិតធំៗចំនួនបីសារ (ថ្ងៃ)ដោយ ឆ្កឹះចៀថ្នមៗយកកញ្ចុំដែលមានផ្សិតធំនៅថ្ងៃទី១ និង ថ្ងៃទី២តែនៅថ្ងៃទីបីត្រូវឆ្កឹះដក ទាំងធំទាំងតូច

## ការប្រមូលផល (ត)

- បន្ទាប់មកគេ បាញ់ផ្សើមទឹកដី កំប៉ុស្តិលើដុំល្បាយ ដែលបេះ អស់និមួយៗ ហើយបន្តថែទាំ កំដៅ និងសំណើម

- តាម ធម្មតាក្នុង១សារ

(វដ្តផ្សិត) មាន រយៈពេលសរុបពី ៣០ទៅ៤៥ថ្ងៃ គេប្រមូលផលផ្សិត បានពី៥ខាំ ទៅ១គីឡូក្រាមពីដុំល្បាយមួយដុំ

# សូមអរគុណសំរាប់ការចូលរួមស្តាប់របស់លោក-លោកស្រី




ផលិតផលដែលគ្មានជាតិគីមី